ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១៦១/០៩-សិប្បកម្មព្រែកត្រែង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **កៅ ថាច**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **វ៉ែន ពៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន **សិប្បកម្មព្រែកត្រែង**

អាសយដ្ឋាន : ភូមិព្រែកត្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩៣១ ៣៧៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក : **អវត្តមាន**

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃសិប្បកម្ម ព្រែកត្រែង**

អាសយដ្ឋាន : ផ្ទះលេខ៥២-៣ G ផ្លូវ២៦ BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ២៨២ ៦៥៣ លេខទូរសារ : គ្មាន

បណ្តុំមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phnom Penh • Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតៈ

១- លោក អ៊ុំ វិសាល — មន្ត្រីច្បាប់នៃសម្ព័ន្ធសហជីព ស៊ីខៅឌូ

២- លោក ធួក ចំរើន — ប្រធានសហជីព ស៊ីខៅឌូ នៃសិប្បកម្មព្រែកព្រែង

៣- កញ្ញា សែន សុពេញ — អនុប្រធានសហជីព

៤- លោក អាន ហ៊ាង — ទីប្រឹក្សាសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- នៅពេលកម្មករឈឺមានសំបុត្រពេទ្យ ដោយមានបោះត្រាប្រចាំគ្លីនិក ឬមណ្ឌលសុខភាព សូមឱ្យក្រុមហ៊ុន រក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ ។ ភាគីក្រុមហ៊ុនទទួលស្គាល់តែត្រាប្រាសាទកំពូលបី (ស្ថាប័នរដ្ឋ) ។

២- ស្នើឱ្យក្រុមហ៊ុនធ្វើកាតជូនកម្មករឡើងវិញ ដោយមានឈ្មោះក្រុមហ៊ុន ឈ្មោះកម្មករ អត្តលេខ ផ្នែក និងថ្ងៃ ខែ ឆ្នាំចូលធ្វើការ តាំងពីលើកដំបូងឱ្យបានត្រឹមត្រូវ ។ ប្រសិនបើខុសកម្មករអាចទៅជួបផ្នែករដ្ឋបាលរបស់ក្រុមហ៊ុន ដើម្បីសុំឱ្យក្រុមហ៊ុនធ្វើកាតជូនកម្មករឡើងវិញ ។ ភាគីក្រុមហ៊ុនមិនលទ្ធភាពប្តូរឈ្មោះក្រុមហ៊ុនបានទេ ។

៣- ស្នើឱ្យក្រុមហ៊ុនរៀបចំបោះឆ្នោតជ្រើសរើសតំណាងកម្មករឱ្យបានឆាប់បំផុត ។ ភាគីក្រុមហ៊ុននិងបោះឆ្នោតជ្រើសរើសតំណាងកម្មករ នៅពេលដែលសិប្បកម្មនេះប្តូរឈ្មោះក្រុមហ៊ុន ។

៤- ស្នើឱ្យក្រុមហ៊ុនផ្តល់លុយបាយបន្ថែមចំនួន ៥០០ រៀល ក្នុងមួយខែ បន្ថែមលើលុយបាយសព្វថ្ងៃ ។ ភាគីក្រុមហ៊ុនមិនមានលទ្ធភាព ។

៥- ស្នើឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលក្នុងខែសីហាឡើងវិញ ដែលក្រុមហ៊ុនទូទាត់ខុស ។ ភាគីក្រុមហ៊ុនបញ្ជាក់ថា ប្រាក់ក្នុងខែសីហា បានគិតប្រាក់ឈ្នួលត្រឹមត្រូវហើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៤៧៧/០៩ កប/កណ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ (វេលាម៉ោង ១៤:00 នាទី រសៀល) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន០៨ចំណុច ដែលជាការទាមទាររបស់កម្មករនិយោជិតនៃសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំសិប្បកម្មព្រែកត្រែង ។ យោងទៅលើការផ្សះផ្សាលើចំណុចមិនសះជានេះ ជាលទ្ធផល បានទទួលចំណុចសះជានឹងគ្នាចំនួន០៣ចំណុច និងចំណុចមិនសះជាចំនួន០៥ចំណុច លើការទាមទារចំនួន០៨ចំណុច ។ ចំណុចមិនសះជាចំនួន០៥ចំណុចនេះត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន០៥ចំណុចនេះនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង០២:០០នាទីរសៀល ។ ភាគីទាំងពីរ មានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ អ្នកតំណាងនិយោជក ដែលអញ្ជើញមកពីក្រុមហ៊ុនសិប្បកម្មព្រែកត្រែងមិនបានចូលរួមសវនាការទេ ដោយមូលហេតុអ្នកតំណាងរូបនេះ ពុំមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវពីនិយោជកនៃក្រុមហ៊ុន សិប្បកម្មព្រែកត្រែង ។ ហេតុនេះហើយ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើសវនាការដោយកំបាំងមុខចំពោះភាគីក្រុមហ៊ុន ។ នៅពេលសវនាការ ភាគីកម្មករនិយោជិតបានព្រមព្រៀង និងឯកភាពដកចំណុចវិវាទទី ៣ និងចំណុចវិវាទទី ៤ ចេញពីការទាមទារ ដោយលើកមូលហេតុថា ចំណុចវិវាទទាំងនេះ មានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន និងកម្មករនិយោជិតរួចហើយ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទដែលនៅសល់ ដែលមានចំណុចវិវាទទី១, ទី២ និងទី៥ ដោយផ្អែកលើភស្តុតាង និងហេតុផល ដូចខាងក្រោម:

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ឧទ្ធរណ៍ ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- តារាងប្រាក់បៀវត្សឈ្មោះ អាន ហៀន ។

២- សារណាការពារ លេខ ១៣៣/០៩ ស.ប.ក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ លើសំណុំរឿង ១៦១/០៩-សិប្បកម្មព្រែកត្រែង។

៣- កំណត់ហេតុចរចារដោះស្រាយវិវាទនៃសិប្បកម្មព្រែកត្រែង ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ។

៤- ពាក្យសុំចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃសិប្បកម្មព្រែកត្រែង ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ។

៥- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមសិប្បកម្មព្រែកត្រែង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ។

៦- តារាងដែលកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលឡើងវិញ ដែលក្រុមហ៊ុនបានទូទាត់ខុសក្នុងខែសីហា ឆ្នាំ២០០៩ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅសិប្បកម្មព្រែកត្រែង លេខ ៤៧៧/០៩ កប/កណ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់សិប្បកម្មព្រែកត្រែង ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០០៩។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨៣១ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៣២ កប/អក/វក/លកអ. ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៩។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន សិប្បកម្មព្រែកត្រែង មានទីតាំងស្ថិតនៅភូមិព្រែកត្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល មានជួលកម្មករនិយោជិតសរុបចំនួន ១ ២០០ នាក់ ។

- នៅក្នុងក្រុមហ៊ុន សិប្បកម្មព្រែកព្រែង នេះ មានសហជីពចំនួន២ គឺសហជីពយុវជនខ្មែរ និងសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ (ស៊ីខៅឌូ) ។
- ក្រុមហ៊ុន សិប្បកម្មព្រែកព្រែង មិនទាន់បានចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួននៅឡើយទេ ។
- ភាគីកម្មករនិយោជិត ដែលភាគីនៃដើមបណ្តឹងក្នុងរឿងនេះ តំណាងដោយសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ (ស៊ីខៅឌូ) ហើយសហជីពនេះកំពុងតែស្ថិតនៅក្នុងដំណើរការសុំចុះបញ្ជិកា នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលសហជីពនេះ បានដាក់ជូននៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ។

**ចំណុចវិវាទទី ១ : នៅពេលដែលកម្មករនិយោជិតឈឺ សុំឱ្យក្រុមហ៊ុនទទួលស្គាល់សំបុត្រពេទ្យដោយមានបោះត្រាប្រចាំគ្លីនិក ឬមណ្ឌលសុខភាព**

- កម្មករនិយោជិតលើកឡើងថា ការអនុវត្តរបស់ក្រុមហ៊ុនកន្លងមក គឺនៅពេលដែលកម្មករនិយោជិតមានជំងឺ ហើយសុំច្បាប់ទៅក្រុមហ៊ុន គឺក្រុមហ៊ុនទទួលស្គាល់តែសំបុត្រពេទ្យមកពីស្ថាប័នរដ្ឋប៉ុណ្ណោះ ។ បន្ទាប់មកនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ កម្មករនិយោជិត និងនិយោជកបានធ្វើកិច្ចព្រមព្រៀងមួយ ដែលចែងថា "ក្រុមហ៊ុនឯកភាពអនុញ្ញាតច្បាប់ជូនកម្មករតាមវេជ្ជបញ្ជារបស់គ្រូពេទ្យ" ។ ប៉ុន្តែភាគីក្រុមហ៊ុនមិនដែលបានអនុវត្តលើកិច្ចព្រមព្រៀងនេះទេ ហេតុនេះហើយ ភាគីកម្មករនិយោជិតសុំឱ្យក្រុមហ៊ុនអនុវត្តនូវកិច្ចព្រមព្រៀងនេះដែលមានស្រាប់ ឧទាហរណ៍ដូចករណី កម្មករនិយោជិតឈ្មោះ ជឿន ចាន់នី ភេទស្រី អាយុ ២៧ ឆ្នាំ បានសុំច្បាប់សម្រាកលំហែមាតុភាព ដោយមានសំបុត្រពេទ្យ ដែលចេញដោយមណ្ឌលសុខភាព ស្វាយប្រទាល តែនិយោជកពុំព្រមអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកទេ ដោយពួកគាត់លើកឡើងថា ក្រុមហ៊ុនទទួលស្គាល់តែសំបុត្រពេទ្យ ដែលចេញដោយស្ថាប័នរដ្ឋតែប៉ុណ្ណោះ ។
- រាល់ការលើកឡើង និងបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចទទួលបាននូវការបញ្ជាក់តបពីភាគីនិយោជកទេ ដោយហេតុថា ភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការ ។

**ចំណុចវិវាទទី ២ : កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនធ្វើកាតជូនកម្មករឡើងវិញ ដោយមានឈ្មោះក្រុមហ៊ុន ឈ្មោះកម្មករ អត្តលេខ ផ្នែក និងថ្ងៃខែឆ្នាំ ចូលធ្វើការតាំងពីលើកដំបូងឱ្យបានត្រឹមត្រូវ**

- ភាគីកម្មករនិយោជិតបានលើកឡើងថា នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ភាគីកម្មករនិយោជិត និងនិយោជកបានធ្វើកិច្ចព្រមព្រៀងមួយ ដោយនិយោជកសន្យាយល់ព្រមធ្វើកាត ដោយមានឈ្មោះក្រុមហ៊ុន ឈ្មោះកម្មករ អត្តលេខ ផ្នែក និងថ្ងៃខែឆ្នាំ ចូលធ្វើការតាំងពីលើកដំបូង ។ ប៉ុន្តែភាគីក្រុមហ៊ុនពុំបានអនុវត្តដូចអ្វីដែលភាគីបានធ្វើកិច្ចព្រមព្រៀងនោះទេ ។ ហេតុដូចនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនអនុវត្តនូវកិច្ចព្រមព្រៀង ដែលភាគីទាំង២បានធ្វើកន្លងមក ។

- នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ភាគីកម្មករនិយោជិត និងនិយោជក បានធ្វើកិច្ចព្រមព្រៀងមួយស្តីពីការធ្វើកាតជូនកម្មករនិយោជិត ដែលចែងថា "*ក្នុងរយៈពេល២ខែ ក្រុមហ៊ុនឯកភាពធ្វើកាតជូនកម្មករឡើងវិញ ដោយមានឈ្មោះក្រុមហ៊ុនត្រឹមត្រូវ មានឈ្មោះកម្មករ អត្តលេខ ផ្នែក និងថ្ងៃចូលធ្វើការរបស់កម្មករ ក្នុងករណីកម្មករណាម្នាក់ ដែលក្រុមហ៊ុនដាក់ថ្ងៃចូលធ្វើការដំបូងខុស កម្មករអាចទៅជួបផ្នែករដ្ឋបាល ឬផ្នែកសហជីព*" ។
- រាល់ការលើកឡើង និងបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចទទួលបាននូវការបញ្ជាក់តបពីភាគីនិយោជកទេ ដោយហេតុថា ភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការ ។

**ចំណុចវិវាទទី ៥ : ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលខែសីហា ឆ្នាំ២០០៩ ឡើងវិញ ដែលក្រុមហ៊ុនបានទូទាត់ខុស**

- ភាគីកម្មករនិយោជិតបានលើកឡើងថា ក្រុមហ៊ុនបានគិតប្រាក់ឈ្នួលខុសនៅក្នុងខែសីហាកន្លងមក។ កម្មករនិយោជិតបានបាត់ប្រាក់ឈ្នួលរបស់គាត់ ហើយបានស្នើសុំទៅជួបគណនេយ្យរបស់ក្រុមហ៊ុន ដើម្បីសួរបញ្ជាក់ ប៉ុន្តែគណនេយ្យរបស់ក្រុមហ៊ុនពុំបានពន្យល់លំអិតទេ ហេតុនេះហើយ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួលក្នុងខែសីហា ឆ្នាំ២០០៩ ឡើងវិញ។
- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតពុំបានពន្យល់ក្បោះក្បាយពីមូលហេតុ ដែលក្រុមហ៊ុនគិតលុយខ្វះ និងវិធីគណនាលុយ ដែលពួកគាត់ត្រូវបានទទួលនោះទេ។ ប៉ុន្តែកម្មករនិយោជិតបានបញ្ជាក់ថា មូលហេតុនៃការទាមទារនេះ ដោយយោងទៅលើទឹកប្រាក់ ដែលពួកគាត់ត្រូវទទួលបាន ដូចជា ទឹកប្រាក់ ដែលពួកគាត់ដេរសីឡូ មានលុយព្រឹម លុយដែលពួកគាត់ធ្វើការថ្ងៃបុណ្យ... ។ល។
- នៅក្នុងករណីនេះ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរធ្វើការទាមទារសម្រាប់កម្មករនិយោជិតទូទាំងរោងចក្រ ព្រោះក្រុមហ៊ុនបានគិតប្រាក់ឈ្នួលនេះខុសទូទាំងរោងចក្រ ប៉ុន្តែសហជីពនេះ ពុំបានបញ្ជាក់ពីចំនួនកម្មករនិយោជិត ដែលធ្វើការទាមទារនេះទេ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីកម្មករនិយោជិតផ្តល់ចំនួនកម្មករនិយោជិតជាក់លាក់ ដែលធ្វើការទាមទារនៅក្នុងចំណុចវិវាទនេះ ដោយថែមទាំងមានលិខិតផ្ទេរសិទ្ធិពីពួកគាត់, ចំនួនទឹកប្រាក់ដែលពួកគាត់បានបាត់ និងវិធីគណនាមកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩។
- នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលតារាង ដែលកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលឡើងវិញ ដែលក្រុមហ៊ុនបានទូទាត់ខុសក្នុងខែសីហា ឆ្នាំ២០០៩។ ក្នុងនោះក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញពីចំនួនកម្មករនិយោជិត ដែលធ្វើការទាមទារនេះ មានចំនួន ៩៦នាក់ ប៉ុន្តែកម្មករនិយោជិតទាំង៩៦នាក់នោះ ពុំបានធ្វើលិខិតផ្ទេរសិទ្ធិជូនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរទេ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

មុននឹងពិចារណាលើចំណុចទាមទារនៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើសមាសភាពនៃភាគីនៅក្នុងវិវាទនេះជាមុនសិន។

យោងតាមអង្គហេតុ ក្រុមហ៊ុន សិប្បកម្មព្រែកព្រែង មានជូលកម្មករនិយោជិតសរុបចំនួនប្រហែល ១ ២០០ នាក់ ប៉ុន្តែក្រុមហ៊ុននេះមិនទាន់បានចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួននៅក្រសួងពាណិជ្ជកម្មនៅឡើយទេ ប៉ុន្តែភាគីតំណាងក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនកំពុងតែស្ថិតនៅក្នុងដំណើរការចុះបញ្ជិកា។

នៅថ្ងៃសវនាការ អ្នកតំណាងរបស់ក្រុមហ៊ុន ដែលមានឈ្មោះលោក អោក ហួរ និងលោក ម៉ាក់ សុភ័ក្រ បានមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែអ្នកតំណាងទាំង០២រូបនេះពុំមានលិខិតផ្ទេរសិទ្ធិពីនិយោជកនៃក្រុមហ៊ុន សិប្បកម្មព្រែកព្រែងទេ ដោយមូលហេតុថា និយោជកជាប់បំពេញភារកិច្ចនៅក្រៅប្រទេស។ ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានសំណូមពរឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើសវនាការកំបាំងមុខ។ ដោយហេតុនេះហើយ ទើបអ្នកតំណាងដែលអញ្ជើញមកពីក្រុមហ៊ុន សិប្បកម្មព្រែកព្រែង បានសម្រេចមិនបន្តចូលរួមសវនាការរបស់អាជ្ញាកណ្តាលរហូតដល់ចប់ឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោមៈ

ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម...ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

យោងតាមប្រការ ១៩ នៃប្រកាសលេខ ៩៩/០៤ នៃប្រកាសខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា **"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"** បានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួនក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាបុគ្គលនោះទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ។

នៅក្នុងសេចក្តីបង្គាប់លេខ ៧១/០៨-វីវីវីច ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការបកស្រាយថា *"មិនឃើញមានលិខិតផ្ទេរសិទ្ធិពី លោក SUNG CHUNG KWUN ឬនាយកប្រតិបត្តិណាមួយរបស់ក្រុមហ៊ុន នៅកម្ពុជាផ្ទេរសិទ្ធិជូនលោក Albert Cheung ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងពីរខាងលើផងដែរ។ តាមន័យនេះ លោក Albert Cheung មិនអាចត្រូវបានចាត់ទុកជាតំណាងស្របច្បាប់ ឬអាណត្តិគាហករបស់ក្រុមហ៊ុន វីវីវីច នៅកម្ពុជាឡើយ"*។

នៅក្នុងករណីនេះ លោក អោក ហួរ និងលោក ម៉ាក់ សុភ័ក្រ បានមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែអ្នកតំណាងទាំង០២រូបនេះពុំមានលិខិតផ្ទេរសិទ្ធិពីនិយោជកទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លោក អោក ហួរ និងលោក ម៉ាក់ សុភ័ក្រ ដែលមិនមែនជាភាគីវិវាទនៅក្នុងសំណុំរឿងនេះ

មិនបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីនិយោជក ដើម្បីធ្វើជាតំណាងស្របច្បាប់ ដើម្បីដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការសម្រេចដោយអវត្តមានរបស់ភាគីនិយោជក។

ទន្ទឹមនឹងនេះដែរ ភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ គឺ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ (ស៊ីខៅឌូ) ដែលកំពុងតែស្ថិតនៅក្នុងដំណើរការចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចនេះ សហជីពនេះ ពុំទាន់ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជិកានៅឡើយទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើសហជីពនេះ មានសិទ្ធិតំណាងឱ្យសមាជិករបស់ខ្លួន ក្នុងការនាំវិវាទការងាររួមមកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដែរ ឬទេ?

មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារចែងថា *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ការងារនេះទទួលស្គាល់ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនេះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាលទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីសុំចុះបញ្ជិកា។...*

*ក្នុងរយៈពេលពីរខែ ក្រោយពីបានទទួលសំណុំបែបបទសុំចុះបញ្ជិកា បើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតប ត្រូវចាត់ទុកអង្គការវិជ្ជាជីវៈនោះថា បានចុះបញ្ជិការួចហើយ..."*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៦៨ ខាងលើនេះ មានន័យថា អង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារទទួលស្គាល់ នៅពេលដែលអង្គការវិជ្ជាជីវៈនោះទទួលបានការចុះបញ្ជិកានៅក្រសួងទទួលបន្ទុកវិស័យការងារ។

នៅក្នុងករណីនេះ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ បានធ្វើសំណើសុំចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួចហើយ ហើយកំពុងតែស្ថិតនៅក្នុងការរង់ចាំ។ ដូចនេះ សហជីពនេះពុំទាន់បានទទួលវិញ្ញាបនប័ត្រចុះបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឡើយទេ។ ដូច្នេះ យោងតាមមាត្រា ២៦៨ ខាងលើ សហជីពនេះមិនទាន់បានទទួលនូវសិទ្ធិ និងផលប្រយោជន៍តាមច្បាប់ស្តីពីការងារឡើយ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញដែរថា សិទ្ធិ និងផលប្រយោជន៍នេះ រួមបញ្ចូលទាំងសិទ្ធិរបស់សហជីពក្នុងការតំណាងសមាជិករបស់ខ្លួន មកដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៦២/០៦-ឃ្វីកស៊ូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២, លេខ ៣០/០៨-អ៊ី ហ្គាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១, លេខ ៣១/០៨-សៅធនី ស៊ើរ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និងលេខ ១២០/០៩-រីឡាយអេប៊ិល*)។

ដូចនេះ សហជីពនេះពុំមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីយកវិវាទមកដោះស្រាយតាងនាមឱ្យសមាជិករបស់ខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។

បន្ថែមពីនេះ ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬ ដោយមានអ្នកអម...ឬ ដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

នៅក្នុងសវនាការ មានវត្តមានរបស់កម្មករនិយោជិតចំនួន ០៣ នាក់ គឺកម្មករ ធូក ចំរើន, កម្មករ សែន សុពេញ និងកម្មករ អាន ប៉ាង។ ក្នុងករណីនេះ ភាគីសហជីពបានបង្ហាញថា សមាជិកសហជីពនៅក្នុងក្រុមហ៊ុនសិប្បកម្មព្រែកត្រែង មានចំនួនប្រហែលជា៧០០នាក់ ហើយកម្មករនិយោជិតទាំងអស់ ដែលធ្វើការទាមទារនៅក្នុងសំណុំរឿងនេះ ដោយមានស្នាមផ្តិតមេដៃផងនោះមានចំនួនប្រហែលជា១០០០នាក់។ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបានសន្យាថា នឹងផ្ញើលិខិតផ្ទេរសិទ្ធិរបស់កម្មករនិយោជិត ដែលធ្វើការទាមទារនោះ មកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩។ ប៉ុន្តែ មកដល់ថ្ងៃកំណត់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពុំបានទទួលនូវលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត ដែលជាដើមបណ្តឹងនោះទេ។ ដូច្នេះ យោងតាមប្រការ ១៩ នៃប្រកាសលេខ ៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំពោះកម្មករនិយោជិត ៣ នាក់ ដែលជាភាគីវិវាទ ដោយមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។

**ចំណុចវិវាទទី ១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលស្គាល់សំបុត្រពេទ្យដោយមានបោះត្រាប្រចាំគ្លីនិក ឬមណ្ឌលសុខភាព នៅពេលកម្មករនិយោជិតឈឺ**

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកសំបុត្រពេទ្យផ្លូវការពីស្ថាប័នរដ្ឋ និងស្ថាប័នឯកជន នៅពេលដែលកម្មករនិយោជិតសុំច្បាប់សម្រាកមានជម្ងឺ។ ភាគីនិយោជកជំទាស់នឹងការទាមទារនេះ ដោយទទួលស្គាល់តែពីមន្ទីរពេទ្យពីស្ថាប័នរដ្ឋប៉ុណ្ណោះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើការដែលនិយោជកទទួលស្គាល់ត្រា ដែលចេញដោយមន្ទីរពេទ្យរបស់ស្ថាប័នរដ្ឋត្រឹមត្រូវ ឬ ទេ?

មាត្រា ៧១ ចំណុចទី៣ នៃច្បាប់ស្តីពីការងារចែងថា *"កិច្ចសន្យាការងារត្រូវព្យួរដោយមូលហេតុ ដូចខាងក្រោម....អវត្តមាននៃកម្មករនិយោជិតក្នុងករណីមានជម្ងឺ ដែលមានគ្រូពេទ្យផ្លូវការបានបញ្ជាក់ត្រឹមត្រូវ។ ថិរវេលាអវត្តមាននោះ ត្រូវមានកំណត់ត្រឹមប្រាំមួយខែ ប៉ុន្តែអាចពន្យាររហូតដល់មានអ្នកជំនួស...."* ។

តាមរយៈមាត្រានេះ កិច្ចសន្យាការងាររបស់កម្មករនិយោជិតត្រូវបានព្យួរ នៅពេលដែលកម្មករនិយោជិតឈឺ ហើយមានគ្រូពេទ្យផ្លូវការទទួលស្គាល់។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គ្រូពេទ្យផ្លូវការ គឺគ្រូពេទ្យដែលទទួលការបណ្តុះបណ្តាលពីសាលាពេទ្យ ដែលទទួលស្គាល់ពីក្រសួងសុខាភិបាល មានសញ្ញាប័ត្របញ្ជាក់ត្រឹមត្រូវ និងមានលិខិតអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈដោយក្រសួងសុខាភិបាល *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០២/០៧*

*-តេវ៉ាតិច្ស ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី២ និងលេខ ៧២/០៨-យ៉ុង វ៉ា ២ ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៣)* ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ឯកភាពលើការបកស្រាយខាងលើដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា **"មន្ទីរពេទ្យរដ្ឋ"** មានមន្ទីរពេទ្យបង្អែកខេត្ត-ក្រុង មន្ទីរពេទ្យបង្អែកស្រុក មន្ទីរពេទ្យបង្អែកខណ្ឌ មណ្ឌលសុខភាពឃុំ មណ្ឌលសុខភាពសង្កាត់ផងដែរ ដែលស្ថិតក្រោមរចនាសម្ព័ន្ធសុខាភិបាលជាតិ ជាពិសេសក្រសួងសុខាភិបាល។ ហេតុនេះហើយ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមមាត្រា ៧១ ចំណុចទី៣ នៃច្បាប់ស្ដីពីការងារ គឺក្រុមហ៊ុនត្រូវទទួលស្គាល់សំបុត្រពេទ្យពីមន្ទីរពេទ្យបង្អែកខេត្ត-ក្រុង មន្ទីរពេទ្យបង្អែកស្រុក មន្ទីរពេទ្យបង្អែកខណ្ឌ មណ្ឌលសុខភាពឃុំ មណ្ឌលសុខភាពសង្កាត់ទាំងអស់ ដោយមិនកំណត់តែមន្ទីរពេទ្យណាមួយនោះទេ។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ឃើញដែរថា ក្រុមហ៊ុនត្រូវទទួលយកលិខិតរបស់គ្រូពេទ្យ ដែលទទួលការបណ្ដុះបណ្ដាលតាមក្របខ័ណ្ឌក្រសួងសុខាភិបាល ហើយមានសញ្ញាប័ត្រត្រឹមត្រូវ និងដែលត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ជាគ្រូពេទ្យព្យាបាលជម្ងឺនៅពេទ្យរដ្ឋ ឬឯកជន។

លើសពីនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ កម្មករនិយោជិត និងនិយោជកបានធ្វើកិច្ចព្រមព្រៀងមួយ ដែលចែងថា *"ក្រុមហ៊ុនឯកភាពអនុញ្ញាតច្បាប់ជូនកម្មករតាមវេជ្ជបញ្ជារបស់គ្រូពេទ្យ"* ។

នៅក្នុងសេចក្ដីបង្គាប់លេខ ២៤/០៥-វ៉េវវ៉ែល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា *"ក្រុមហ៊ុន និងសហជីពសេរីកម្មករប្រចាំរោងចក្រ បានបង្កើតកិច្ចព្រមព្រៀងមួយចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៥ ដែលនៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីនិយោជកបានយល់ព្រមបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតនៅថ្ងៃទី០៧ រៀងរាល់ខែ ... ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីនិយោជក និងកម្មករនិយោជិត ជាប់កាតព្វកិច្ចគោរពតាមកិច្ចព្រមព្រៀងនេះ(សូមមើលសេចក្ដីបង្គាប់លេខ ២៤/០៥-វ៉េវវ៉ែល ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៤)"* ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីទាំងពីរត្រូវតែអនុវត្តតាមកិច្ចព្រមព្រៀងដែលខ្លួនបានចុះឱ្យបានត្រឹមត្រូវ។

សរុបសេចក្ដីមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចឱ្យក្រុមហ៊ុនទទួលស្គាល់លិខិតបញ្ជាក់របស់គ្រូពេទ្យដែលទទួលការបណ្ដុះបណ្ដាលតាមក្របខ័ណ្ឌក្រសួងសុខាភិបាល ហើយមានសញ្ញាប័ត្រត្រឹមត្រូវ និងត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈសំរាប់ជាមូលដ្ឋាននៃការឈប់សម្រាកព្យាបាលជម្ងឺ។

**ចំណុចវិវាទទី ២ : កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនធ្វើកាតជូនកម្មករឡើងវិញ ដោយមានឈ្មោះក្រុមហ៊ុន ឈ្មោះកម្មករ អត្តលេខ ផ្នែក និងថ្ងៃខែឆ្នាំ ចូលធ្វើការតាំងពីលើកដំបូងឱ្យបានត្រឹមត្រូវ**

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុនអនុវត្តនូវកិច្ចព្រមព្រៀង ដែលបានចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ដែលភាគីកម្មករនិយោជិត និងនិយោជកបានធ្វើ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញា

កណ្តាលនឹងធ្វើការពិចារណាដូចខាងក្រោមៈ

មាត្រា ២ នៃច្បាប់ស្តីពីការងារចែងថា *"..... សហគ្រាសនីមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក"* ។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ នៃច្បាប់ស្តីពីការងារនេះមានន័យថា ភាគីនិយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាសិទ្ធិនេះ ធ្វើឡើងដោយស្របច្បាប់ និងសមហេតុសមផល (សូមមើលសេចក្តីបង្គាប់លេខ *១៧/០៣ និង១៨/០៣-ហ្វូ ហ៊ីង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៥, លេខ ២៨/០៤-សណ្ឋាគារ រ៉ាហ្វល ប្រ្គង់ ដង់គរ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២, លេខ ២០/០៦-ញូស្តារ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥, លេខ ១៧/០៧-ឆាមចិចថាយ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ និងលេខ១១៦/០៧-ប្រេ្គសសាន់ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់អាជ្ញាកណ្តាលមុនដែរ ពោល គឺ សិទ្ធិចាត់ចែងរបស់និយោជក រួមមានសិទ្ធិក្នុងការធ្វើកាតជូនកម្មករនិយោជិតផងដែរ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ភាគីកម្មករនិយោជិត និងនិយោជកបានធ្វើកិច្ចព្រមព្រៀងមួយជាមួយគ្នា ដែលភាគីក្រុមហ៊ុនសន្យាថា *"ក្នុងរយៈពេល២ខែ ក្រុមហ៊ុនឯកភាពធ្វើកាតជូនកម្មករឡើងវិញ ដោយមានឈ្មោះក្រុមហ៊ុនត្រឹមត្រូវ មានឈ្មោះកម្មករ អត្តលេខ ផ្នែក នឹងថ្ងៃចូលធ្វើការរបស់កម្មករ ក្នុងករណីកម្មករណាម្នាក់ដែលក្រុមហ៊ុនដាក់ថ្ងៃចូលធ្វើការដំបូងខុស កម្មករអាចទៅជួបផ្នែករដ្ឋបាល ឬផ្នែកសហជីព"*។ ក្នុងករណីនេះ ភាគីក្រុមហ៊ុនបានធ្វើកាតនេះ ជូនកម្មករនិយោជិតពិតប្រាកដមែន ប៉ុន្តែភាគីក្រុមហ៊ុនមិនបានដាក់នូវអ្វី ដែលជាចំណុចចង់បានតាមការព្រមព្រៀងរបស់គូភាគីទេ ។

ដោយហេតុថា ភាគីទាំងពីរមានកិច្ចព្រមព្រៀងជាមួយគ្នា ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរត្រូវតែអនុវត្តតាមកិច្ចព្រមព្រៀង ដែលខ្លួនបានចុះឱ្យបានត្រឹមត្រូវ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យនិយោជកធ្វើកាតជូនកម្មករ ដោយមានឈ្មោះក្រុមហ៊ុន ឈ្មោះកម្មករ អត្តលេខ ផ្នែក និងថ្ងៃខែឆ្នាំ ចូលធ្វើការតាំងពីលើកដំបូង ។

**ចំណុចវិវាទទី ៩ : ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលខែសីហា ឆ្នាំ២០០៩ ឡើងវិញ ដែលក្រុមហ៊ុនបានទូទាត់ខុស**

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួលក្នុងខែសីហា ឆ្នាំ២០០៩ ឡើងវិញ ដែលក្រុមហ៊ុនបានគិតខុសកន្លងមក ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោមៈ

មាត្រា ១១៨ នៃច្បាប់ស្តីពីការងារចែងថា *"ក្នុងករណីមានការប្តឹងជំទាស់អំពីរឿងប្រាក់ឈ្នួល គឺនិយោជកដែលជាអ្នកត្រូវផ្តល់ភស្តុតាងនៃការសងប្រាក់ឈ្នួលរួច...."* ។

នៅក្នុងករណីនេះ ភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការដើម្បីធ្វើការឆ្លើយបំភ្លឺទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពបានផ្តល់តារាងប្រាក់ឈ្នួលរបស់កម្មករនិយោជិតចំនួន ៥៦ នាក់ ដែលទាមទារឱ្យនិយោជកទូទាត់ប្រាក់ឈ្នួលខុសឡើងវិញនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតទាំងនេះ ពុំបានធ្វើលិខិតផ្ទេរសិទ្ធិជូនសហជីព ដើម្បីនាំបណ្តឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ យោងតាមប្រការ ១៩ នៃប្រកាសលេខ ៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំពោះកម្មករនិយោជិតដែលជាភាគីវិវាទដែលបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ប៉ុណ្ណោះ (*សូមមើលការបកស្រាយរបស់អាជ្ញាកណ្តាលនៅហេតុផលនៃសេចក្តីសម្រេចខាងលើ*)។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា មានកម្មករនិយោជិតចំនួន០២នាក់ ដែលមានវត្តមាននៅក្នុងសវនាការ ហើយមានឈ្មោះនៅក្នុងតារាងទាមទារឱ្យសងប្រាក់ឈ្នួលនេះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាលើការទាមទាររបស់កម្មករនិយោជិតទាំង០២នាក់ ដែលមានឈ្មោះ ធួក ចំរើន និង អាន ហៀង ដូចតទៅ ៖

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជាកណ្តាលបានកំណត់ថា "*ជាគោលការណ៍ នៅក្នុងករណីដែលកម្មករនិយោជិតធ្វើការទាមទារអំពីបញ្ហាសំណងប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលនិយោជកមិនបានគិតត្រឹមត្រូវ កម្មករនិយោជិតមានកាតព្វកិច្ចត្រូវបញ្ជាក់អំពីចំនួនទឹកប្រាក់ ដែលបានគណនាខុស ខែដែលបានគណនាខុស ភស្តុតាងដែលបញ្ជាក់ថា បានគណនាខុស ។ល។ និង ។ល។ ដើម្បីបញ្ជាក់អំពីអំណះអំណាងរបស់ខ្លួន*" (សូមមើលសេចក្តីបង្គាប់លេខ *២៣/០៨-អឹម និង វ៉ៃ ១ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និងទី១១ និងលេខ ១៣៣/០៩-តាក ហ្វាត ហេតុផលនៃ សេចក្តីសម្រេចចំណុចវិវាទទី ៤*)។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗដែរ គឺភាគីកម្មករនិយោជិតត្រូវផ្តល់ព័ត៌មាន និងភស្តុតាងឱ្យគ្រប់គ្រាន់ និងពន្យល់បញ្ជាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យបានច្បាស់លាស់អំពីការទាមទាររបស់ខ្លួន។

តាមរយៈភស្តុតាង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា កម្មករនិយោជិតឈ្មោះ ធួក ចំរើន អត្តលេខ ១៧៦ F ត្រូវទទួលបានប្រាក់ឈ្នួលសរុបពីនិយោជកចំនួន ៦៥,២៦ដុល្លារអាមេរិក (ប្រាក់ឈ្នួលទាំងនោះមានដូចជា ប្រាក់ឡូ ចំនួនថ្ងៃធ្វើការដែលនិយោជកបានគិត ថ្លៃបន្ថែមម៉ោងធម្មតា ការងាររោងចក្រ ប្រាក់ទ្រទ្រង់ជីវភាព)។ ប៉ុន្តែនិយោជកបើកជូនតែ ៦៣,៧៧ ដុល្លារអាមេរិកប៉ុណ្ណោះ។ ដូច្នេះ និយោជកនៅខ្វះចំនួន ១.៤៩ ដុល្លារអាមេរិកទៀត។ ចំពោះកម្មករនិយោជិត អាន ហៀង អត្តលេខ ១៨១ F វិញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ភស្តុតាងដែលគាត់បានផ្តល់មក គឺគ្រាន់តែបានបង្ហាញពីចំនួនទឹកប្រាក់ឡូ ថ្លៃបន្ថែមម៉ោងធម្មតា ការងាររោងចក្រ ប្រាក់ថ្លៃបាយ និងប្រាក់ទ្រទ្រង់ជីវភាពប៉ុណ្ណោះ។ ប៉ុន្តែកម្មកររូបនេះ មិនបានបង្ហាញពីចំនួនទឹកប្រាក់សរុប ដែលគាត់ត្រូវបានទទួលពីនិយោជក ហើយពុំបានបង្ហាញថា និយោជកបានបើកជូនគាត់នៅខ្វះប៉ុន្មានទៀតដែរ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីធ្វើការពិចារណាលើការ

ទាមទាររបស់កម្មករនិយោជិត អាន ហៀង ទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បញ្ហាប្រាក់ឈ្នួលរបស់កម្មករនិយោជិតនេះ គឺជាការប្រឈមចំបងជាចាំបាច់ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវដោះស្រាយ ប៉ុន្តែការដោះស្រាយបញ្ហាអាចសម្រេចទៅបាន លុះត្រាតែមានអង្គហេតុច្បាស់លាស់ អំណះអំណាង និងភស្តុតាងគ្រប់គ្រាន់របស់កម្មករនិយោជិតម្នាក់ៗ ដែលបញ្ជាក់ថា និយោជកគិតប្រាក់ឈ្នួលរបស់គាត់មិនបានត្រឹមត្រូវ។

នៅក្នុងសេចក្តីបង្គាប់លេខ ១៣៣/០៩-គាក ហ្វាត ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលដែលខ្វះ នៅពេលកម្មករនិយោជិតមិនបានបង្ហាញភស្តុតាងជាក់លាក់អំពីប្រាក់ឈ្នួល ដែលខ្វះ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើជាមូលដ្ឋានដើម្បីសម្រេច (សូមមើលសេចក្តីបង្គាប់លេខ *១៣៣/០៩-គាក ហ្វាត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤*។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល (១)សម្រេចឱ្យក្រុមហ៊ុនសងប្រាក់ឈ្នួលចំនួន ១. ៤៩ ដុល្លារអាមេរិក ជូនកម្មករ ធួក ចំរើន និង(២) បដិសេធការទាមទាររបស់កម្មករ អាន ហៀង ដែលឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលដែលខ្វះសម្រាប់ខែសីហា ឆ្នាំ២០០៩។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ :**

បង្គាប់ឱ្យក្រុមហ៊ុនទទួលស្គាល់លិខិតបញ្ជាក់របស់គ្រូពេទ្យ ដែលទទួលការបណ្តុះបណ្តាលតាមក្របខ័ណ្ឌក្រសួងសុខាភិបាល ហើយមានសញ្ញាប័ត្រត្រឹមត្រូវ និងត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈតាមមន្ទីរពេទ្យរដ្ឋ និងឯកជន។

**ចំណុចវិវាទទី ២ :**

បង្គាប់ឱ្យនិយោជកធ្វើកាត ជូនកម្មករនិយោជិតដោយមានដាក់ឈ្មោះក្រុមហ៊ុន ឈ្មោះកម្មករ អត្តលេខផ្នែក និងថ្ងៃខែឆ្នាំ ចូលធ្វើការតាំងពីលើកដំបូង។

**ចំណុចវិវាទទី ៥ :**

- បង្គាប់ឱ្យក្រុមហ៊ុនសងប្រាក់ឈ្នួលចំនួន១. ៤៩ ដុល្លារអាមេរិក ជូនកម្មករនិយោជិតឈ្មោះ ធួក ចំរើន សម្រាប់ខែសីហា ឆ្នាំ២០០៩។

- បដិសេធការទាមទាររបស់កម្មករនិយោជិត អាន ហៀង ដែលឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល ដែលខ្វះសម្រាប់ខែសីហា ឆ្នាំ២០០៩។

ប្រភេទនៃសេចក្តីបង្គាប់ : **សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **កៅ ចាច**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ម៉ែន ពៅ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------